# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.០១៩៧.សស.ស/ ៦.៣

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុ ឆ្នាំ២០០៧

# សារាចរណែនាំ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ជំរាបមក**

- លោក - ប្រធានមន្ទីរពេទ្យជាតិ - ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
- លោក - លោកស្រីប្រធានមន្ទីរសុខាភិបាលខេត្ត - ក្រុង

**កម្មវត្ថុ** : ការបង្កើនការលើកទឹកចិត្តចំពោះឆ្មប ដោយបង្កើនប្រាក់ឧបត្ថម្ភជូនឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់ ។

**យោង** : -ប្រកាសអន្តរក្រសួង លេខ ២៦៨ សហវ . ហកចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៧ ស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ។

- ការប្រជុំរវាងឯកឧត្តម នុត សុខុម រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាមួយឯកឧត្តម ហង្ស ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៧ នៅទីស្តីការក្រសួងសុខាភិបាល ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបជូនលោក - លោកស្រីប្រធានជ្រាបថា ដើម្បីអនុវត្តការផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប ដែលបានផ្តល់សេវាសំរាលកូនរស់នៅតាមមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ក្នុងគោលបំណងកាត់បន្ថយអត្រា មរណៈមាតា និងទារក ឱ្យបានថយចុះជាអតិបរមា ក្រសួងសុខាភិបាលសុំធ្វើការណែនាំ ទាក់ទងទៅនិងការ ប្រើប្រាស់ប្រាក់ឧបត្ថម្ភដូចតទៅ :

១ - ដើម្បីអនុវត្តការលើកទឹកចិត្តនេះឱ្យមានប្រសិទ្ធិភាព និងតម្លាភាព ប្រធានអង្គភាព :

- អនុវត្តការបែងចែកប្រាក់ឧបត្ថម្ភផ្អែកលើនិយមន័យរបស់ពាក្យ : ក្រុមឆ្មបសំរាលកូន ដែលមានសមាសភាពដូចតទៅ :

ក / ឆ្មបដែលមានសញ្ញាប័ត្រមធ្យម ឬ បឋម

ខ / គិលានុបដ្ឋាកយិកាមធ្យម ឬ បឋមដែលបានបណ្តុះបណ្តាលជំនាញសំរាលកូន ០៤ ខែ

គ / វេជ្ជបណ្ឌិត គ្រូពេទ្យដែលមានជំនាញក្នុងផ្នែកសេវាសម្ភព

-ត្រូវពិនិត្យ និងរៀបចំសារឡើងវិញការបែងចែកឆ្មបដែលមានសមត្ថភាពក្នុងការសំរាលកូន ដែលត្រូវបានតែងតាំងឱ្យទៅបំរើការងារនៅផ្នែកផ្សេងៗ មិនចំទិសដៅឱ្យមកបំរើ

ការងារនៅផ្នែកសម្ភពតាមលទ្ធភាពជាក់ស្តែង ។

២ - នៅតាមមន្ទីរពេទ្យជាតិ - មជ្ឈមណ្ឌលជាតិ - មន្ទីរពេទ្យបង្អែក :

- ករណីសំរាលកូនរស់ធម្មតា : ក្រុមឆ្មបសំរាលកូនទទួលបាន ៩០ %

ក្រុមការងារពាក់ព័ន្ធទទួលបាន ១០ %

- ករណីសំរាលកូនពិបាកដោយមានអន្តរាគមន៍ ប្រធានអង្គភាពសាមីជាអ្នកសំរេចចាត់ចែងប្រាក់ឧបត្ថម្ភនេះឱ្យមានតម្លាភាព

៣ - នៅតាមមណ្ឌលសុខភាព - ប៉ុស្តិ៍សុខភាព :

- ករណីសំរាលកូនរស់ធម្មតា : -ក្រុមឆ្មបសំរាលត្រូវទទួលបាន ៩០ %

-ក្រុមការងារពាក់ព័ន្ធទទួលបាន ១០ %

- ករណីស្ត្រីដែលត្រូវបានបញ្ជូនមកមណ្ឌលសុខភាពដោយឆ្មបបុរាណ ឬដោយអ្នកគាំទ្រសុខភាពភូមិ : -ក្រុមឆ្មបសំរាលត្រូវទទួលបាន ៧០ %

-ក្រុមបញ្ជូនមក និងក្រុមការងារពាក់ព័ន្ធទទួលបាន ៣០ %

៤ - ដើម្បីរៀបចំសំរួលឯកសារឱ្យស្របតាមនិតិវិធីហិរញ្ញវត្ថុនិងរបាយការណ៍ចំនួនកូនកើតរស់ដែលបានសំរាលនៅមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក ត្រូវមានការចុះហត្ថលេខាទទួលថវិការ១០០% ដោយតំណាងក្រុមឆ្មប និងមានការឯកភាពពីប្រធានមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ ឬ ប្រធានមន្ទីរពេទ្យបង្អែក ។

ចំពោះមណ្ឌលសុខភាព ឬ ប៉ុស្តិ៍សុខភាព ត្រូវមានការចុះហត្ថលេខាទទួលថវិការ ១០០% ដោយតំណាងក្រុមឆ្មប និងមានការឯកភាពពីប្រធានមណ្ឌលសុខភាព ឬ ប្រធានប៉ុស្តិ៍ភាព និង ប្រធានឃុំ ឬ ចៅសង្កាត់ ។

- ត្រូវប្រើប្រាស់គំរូស្តង់ដាឯកសារបច្ចេកទេស ដែលបានភ្ជាប់មកជាមួយ ។

៥ - សារាចរណែនាំនេះនឹងមានការកែប្រែក្នុងករណីចាំបាច់ ។

សូមលោក - លោកស្រីប្រធាន អនុវត្តសារាចរណែនាំខាងលើនេះឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុត ។

សូមលោក - លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

វេជ្ជ. នុត-សុខុម

<u>ចំលងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សាលាខេត្ត-ក្រុង
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- នាយកដ្ឋានមន្ទីរពេទ្យ (ដើម្បីជ្រាប)
- គណៈវិជ្ជាជីវៈទាំងអស់
- ឯកសារ-